ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ [illegible] ឧស ......

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹង

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសជម្រាបជូនសាធារណៈជន រូបវន្តបុគ្គល/នីតិបុគ្គល ទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសហការជាមួយកម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) ដែលទទួលជំនួយឥតសំណងពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈ DFAT ក្នុងគោលបំណងធ្វើការសិក្សាឃុំមួយចំនួនដែលពុំទាន់មានទឹកស្អាតប្រើប្រាស់ ដើម្បីរៀបចំឯកសារដាក់ដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅឃុំទាំងនោះ។

ក្រសួងសូមប្រកាសជូនដំណឹងដាក់ដេញថ្លៃជាសាធារណៈ ជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅ **ឃុំស្ពុកប្រវឹក (១-ភូមិស្ពុកប្រវឹក ២-ភូមិបឹងត្របែក ៣-ភូមិកោះធំ ៤-ភូមិប្រឡាយ១៨ និង ៥-ភូមិព្រៃអម្ពាន់) និងឃុំព្រៃត្រលាច (១-ភូមិស្រះថត) ស្រុករុក្ខគិរី ខេត្តបាត់ដំបង** ដែលមានលក្ខខណ្ឌ ដូចខាងក្រោមនេះ ៖

១- ទុនវិនិយោគសរុប៖ **៣៧៤ ៨៤៩** ដុល្លារអាមេរិក សម្រាប់អនុវត្តគម្រោងរយៈពេល ៥ឆ្នាំ
២- អ្នកចូលរួមត្រូវមាន៖ ទុនវិនិយោគយ៉ាងតិច ៣៥% នៃទុនវិនិយោគសរុប
៣- ប្រាក់កក់ធានាចូលរួមដេញថ្លៃ ៖ ៥ ០០០ដុល្លារអាមេរិក (មានលិខិតបញ្ជាក់ពីធនាគារ)
៤- ថវិកាឧបត្ថម្ភពីគម្រោង (3i) ៖ ១០៦ ៤៧២ ដុល្លារអាមេរិក (ឧបត្ថម្ភតាមលទ្ធផលនៃជំហាននីមួយៗ)
៥- ថ្លៃលក់ទឹក (ដេញថ្លៃ) ៖ ចាប់ពី ៤ម៣ ឡើងទៅ ថ្លៃលក់ ចន្លោះពី ២ ២០០៛/ម៣ ដល់ ២ ៥០០៛/ម៣
៦- ព័ត៌មានលម្អិតមានក្នុងឯកសារដេញថ្លៃ ដែលអាចរកជាវបាននៅនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង។ លោកអ្នកក៏អាចស្វែងរកព័ត៌មានសង្ខេបថ្មីសំខាន់ៗ ក្នុងគេហទំព័រ៖ www.3icambodia.org
៧- កិច្ចប្រជុំណែនាំស្តីពីការរៀបចំឯកសារចូលរួមដេញថ្លៃនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣១ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង២ :០០ រសៀល នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ២:០០ រសៀល នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង ជាកំហិត។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ឌិត សុនចាន់


- នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
  លោក សឿង យុត្តិរ៉ា 092 768 699
  អ៊ីម៉ែល៖ yuthera@gmail.com
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង
  លោក រស់ វិសិទ្ធ 012 530 686
- កម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) 012 819 105
  អ៊ីមែល៖ info@3icambodia.org